**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ.ហក

ថ្ងៃទី២៣ ខែ៤ ឆ្នាំ២០០៧

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការផ្តល់ប្រាក់ឧបត្ថម្ភ ឆ្មប

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ០៤.អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋាន មួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- យោងតាមតំរូវការការងារចាំបាច់

**ស ម្រេ ច**

ប្រការ ១.-

ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ថវិការដ្ឋ ក្នុងក្របខ័ណ្ឌនៃឥណទានថវិកា របស់ក្រសួងសុខាភិបាល ដើម្បីឧបត្ថម្ភដល់ឆ្មប ដែលបានផ្តល់សេវាសំរាលកូន នៅតាមមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍ សុខភាព សំដៅកាត់បន្ថយអត្រាមរណៈ មាតា និង ទារក អោយបានថយចុះ ជាអតិបរមា ។

**ប្រការ ២.-**

ឧបត្ថម្ភថវិកា ជូនឆ្មប ដែលបានផ្តល់សេវាសំរាលកូនរស់ នៅតាមមណ្ឌលសុខភាព និងប៉ុស្តិ៍ សុខភាព ក្នុងទារក ០១ នាក់ ចំនួន ៦០.០០០ ៛ ( ហុកសិបពាន់រៀល ) ។

ឧបត្ថម្ភថវិកា ជូនឆ្មប ដែលបានផ្តល់សេវាសំរាលកូនរស់ នៅតាមមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ និងមន្ទីរពេទ្យបង្អែក ក្នុង ទារក ០១ នាក់ ចំនួន ៤០.០០០ ៛ ( សែសិបពាន់រៀល ) ។

**ប្រការ ៣.-**

ការកំណត់លក្ខខ័ណ្ឌផ្សេងៗ ក្នុងការឧបត្ថម្ភថវិកា ជូនឆ្មប ដែលបានផ្តល់សេវាសំរាលកូន នៅតាមសេវាសាធារណៈ មានដូចខាងក្រោម :

- ចំពោះមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ និងមន្ទីរពេទ្យបង្អែក ត្រូវមានឯកសារ ឬ លិខិតស្នាម ចុះហត្ថលេខា តាមឋានានុក្រម សំរេចយល់ព្រមដោយប្រធានអង្គភាព
- ចំពោះមណ្ឌលសុខភាព និង ប៉ុស្តិ៍ សុខភាព ត្រូវមានឯកសារ ឬ លិខិតស្នាម ចុះហត្ថលេខា តាមឋានានុក្រម ដោយមានការឯកភាពពីប្រធានអង្គភាព និង មានការបញ្ជាក់ឯកភាពដោយក្រុមប្រឹក្សា ឃុំ-សង្កាត់
- ចំពោះទារក ដែលបានសំរាលរួចហើយ ហើយស្លាប់ក្នុងពេលសំរាល ឬ ក្នុងរយៈពេលសំរាកថែទាំក្នុងកន្លែងសំរាល មិនត្រូវរាប់បញ្ចូល ក្នុងការផ្តល់ប្រាក់ឧបត្ថម្ភ នេះទេ ។

**ប្រការ ៤.-**

គំរូរបាយការណ៍ និង ឯកសារបច្ចេកទេស ព្រមទាំងលិខិតស្នាម ពាក់ព័ន្ធផ្សេងទៀតត្រូវរៀបចំ ដោយនាយកដ្ឋានមន្ទីរពេទ្យ នៃក្រសួងសុខាភិបាល ។

**ប្រការ ៥.-**

ការទូទាត់ប្រាក់ឧបត្ថម្ភ ដូចមានចែងក្នុងប្រការ ២ ខាងលើនេះ ត្រូវធ្វើឡើងក្នុងមួយត្រីមាសម្តង ក្រោយពីមានរបាយការណ៍ និងឯកសារ ព្រមទាំង លិខិតស្នាម គ្រប់គ្រាន់ត្រឹមត្រូវច្បាស់លាស់ តាមនីតិវិធី ហិរញ្ញវត្ថុ ។

**ប្រការ ៦.-**

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល គ្រប់មន្ទីរសុខាភិបាលខេត្ត-ក្រុង មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍ សុខភាព អង្គភាពពាក់ព័ន្ធទាំងអស់ ដែលស្ថិតនៅក្រោមឱវាទ ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

វេជ្ជ. នុត_សុខុម

**ចម្លងជូន :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង " ដើម្បីជូនជ្រាប "
- រាជកិច្ច
- ដូចប្រការ ៦ " ដើម្បីអនុវត្ត "
- ឯកសារ និងកាលប្បវត្តិ